មិត្តកសិករ

# កិច្ចប្រជុំពិគ្រោះយោបល់
# ស្តីពី
# គំរូមិត្តកសិករ

- កាលបរិច្ឆេទ: ថ្ងៃ ព្រហស្បតិ៍ ទី ០៥ ខែសីហា ឆ្នាំ ២០២១
- ពេលវេលា: ០៩៖០០ ព្រឹក – ១១៖០០ ព្រឹក
- ទីកន្លែង: Zoom Online

KANSAS STATE UNIVERSITY

cirad AGRICULTURAL RESEARCH FOR DEVELOPMENT

iSA innovation for sustainable agriculture

swisscontact

# កម្មវិធីនៃកិច្ចប្រជុំ

| ម៉ោង | ប្រធានបទ | ការពិពណ៌នា | អ្នកទទួលខុសត្រូវ |
|---|---|---|---|
| ៩៖០០ – ៩៖១០ | ការបើកកិច្ចប្រជុំ និងណែនាំខ្លួន | សង្ខេប៖<br>• គោលបំណងនៃកិច្ចប្រជុំ<br>• របៀបវារៈ<br>• លទ្ធផលរំពឹងទុក | អ្នករៀបចំកម្មវិធី |
| ៩៖១០ – ៩៖៣០ | **សុន្ទរកថាស្វាគមន៍** | សុន្ទរកថាស្វាគមន៍ទៅកាន់ក្រុមការងារមិត្តកសិករ | **ឯកឧត្តម បណ្ឌិត ចាន់ សារុទ្ធ**<br>អនុរដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ៩៖៣០ - ៩៖៤៥ | **បទបង្ហាញ៖**<br>ការអភិវឌ្ឍន៍នៃ គំរូមិត្តកសិករ | សង្ខេបអំពីគំរូ និងការវិវឌ្ឍខ្លួនរបស់គម្រូ មិត្តកសិករ បទពិសោធន៍នានា និងបញ្ហាដែលបានជួបប្រទះ ។ល។ | **លោកបណ្ឌិត សេង វ៉ាង**<br>ប្រធាននាយកដ្ឋាន គ្រប់គ្រងធនធានដីកសិកម្ម |
| ៩៖៤៥ – ១០៖០០ | **បទបង្ហាញ៖**<br>ការផ្សព្វផ្សាយបច្ចេក វិទ្យាកសិកម្មអភិរក្ស ក្រោមគម្រូមិត្តកសិករ | សង្ខេបអំពីបច្ចេកវិទ្យាកសិកម្មអភិរក្ស ក្រោមការអនុវត្តនៃគម្រូមិត្តកសិករ | **លោក ងិន កុសល**<br>ប្រធាននាយកដ្ឋាន វិស្វកម្មកសិកម្ម |
| ១០៖០០ – ១០៖១៥ | **បទបង្ហាញ៖**<br>ប្រព័ន្ធនវានុវត្តផ្សព្វផ្សាយកសិកម្មតាម រយៈគម្រូមិត្តកសិករ | សង្ខេបពីគំរូមិត្តកសិករ និងមូលហេតុដែលមិត្តកសិករមានសក្តានុពលសម្រាប់ប្រព័ន្ធនវានុវត្តផ្សព្វផ្សាយកសិកម្ម | **លោក ហេង ជូឡុង**<br>ប្រធានការិយាល័យប្រព័ន្ធសេវាពត៌មានវិទ្យាកសិកម្ម នៃ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ១០៖១៥ – ១០៖២៥ | ចំណាប់អារម្មណ៍ពី លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ការបង្ហាញនូវចំណាប់អារម្មណ៍របស់ លោកប្រធានមន្ទីរលើ គម្រូមិត្តកសិករ | **លោកប្រធានមន្ទីរកសិកម្ម** |
| ១០៖២៥ – ១០៖៤៥ | កិច្ចពិភាក្សា និងមតិយោបល់នៃ អង្គប្រជុំ | ដើម្បីពិភាក្សា ប្រសិនបើមានយោបល់បន្ថែមពីអ្នកចូលរួម | អ្នកចូលរួមកម្មវិធីទាំងអស់ |
| ១០៖៤៥ – ១១៖០០ | ការបិទកិច្ចប្រជុំ | ការសង្ខេប និង មតិបិទកិច្ចប្រជុំ | **ឯកឧត្តម បណ្ឌិត ចាន់ សារុទ្ធ**<br>អនុរដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |



# គោលបំណងនៃកិច្ចប្រជុំ៖

| | |
|---|---|
| 1 | ណែនាំអំពីរចនាសម្ព័ន្ធ ការគ្រប់គ្រង និងក្រុមការងារបច្ចេកទេសនៃគំរូមិត្តកសិករ |
| 2 | ណែនាំអំពីគំរូមិត្តកសិករ និងការច្នៃប្រឌិតថ្មី (នវានុវត្តផ្សព្វផ្សាយកសិកម្ម) |
| 3 | កិច្ចពិភាក្សា ផ្តល់យោបល់ ដើម្បីប្រមូលធាតុចូល និងទិសដៅអនុវត្តបន្ត |



**ឯកឧត្តម បណ្ឌិត ចាន់ សារុទ្ធ**

អនុរដ្ឋលេខាធិកា នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់
និងនេសាទ

# សុន្ទរកថាស្វាគមន៍



# ការបង្ហាញអំពីប្រវត្តិនៃកសិកម្មអតិរក្យ ការផ្សព្វផ្សាយ និង សកម្មភាពសំខាន់ៗនៃការបង្កើតគំរូមិត្តកសិករ


**លោកបណ្ឌិត សេខ វ៉ាង**

ប្រធាននាយកដ្ឋានគ្រប់គ្រងធនធានដី
កសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម
(ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ)

# ទិដ្ឋភាពទូទៅបញ្ហាប្រឈមក្នុងវិស័យកសិកម្ម

មានតម្រូវការសម្រាប់វិស័យកសិកម្មកម្ពុជា ក្នុងការបង្កើតឡើងវិញ ដោយផ្លាស់ប្តូរពីការបង្កើនផលិតកម្មតាមរយៈការ ពង្រីកដីធ្លី និងការប្រើប្រាស់ធាតុចូលច្រើនហួសប្រមាណ ហើយឆ្ពោះទៅរកប្រពលវប្បកម្មនិរន្តរភាព។

- កសិករខ្នាតតូច ងាយរងគ្រោះជាពិសេសចំពោះការប្រែប្រួលអាកាសធាតុ ដោយសារការពឹងផ្អែកខ្ពស់លើរបបទឹកភ្លៀង និងការធ្វើពិពិធកម្មដំណាំតិចតួចបំផុត។
- ដីកសិកម្មនៅប្រទេសកម្ពុជា កំពុងស្ថិតនៅក្រោមការគំរាមកំហែងនៃការរិចរិល និងការបាត់បង់ជីជាតិដី ដោយសារការកាប់បំផ្លាញព្រៃឈើ និងការអនុវត្តការគ្រប់គ្រងដីមិនសមរម្យ។
- ៤៥% នៃផ្ទៃដីនៅកម្ពុជា ស្ថិតនៅក្រោមការរិចរិលពីកម្រិតមធ្យម ទៅខ្លាំង។
- ការចំណាយប្រចាំឆ្នាំនៃការរិចរិលដីនៅកម្ពុជា ត្រូវបានប៉ាន់ប្រមាណថាមានចំនួន ៦៧៧ លានដុល្លារអាមេរិក (GM/UNCCD, ២០១៨).



# តម្រូវការសម្រាប់ដំណោះស្រាយប្រពលវប្បកម្មប្រកបដោយនិរន្តរភាព

ប្រពលវប្បកម្មប្រកបដោយនិរន្តរភាព ផ្តោតទៅលើការប្រើប្រាស់និងការគ្រប់គ្រងធនធានប្រកបដោយប្រសិទ្ធភាព ដែលកសិករអាចទទួលបានទិន្នផលកាន់តែច្រើនដោយប្រើទុនចំណាយទាប ដោយពុំមានការបង្កើនផ្ទៃដី។ CA គឺជាផ្នែកមួយក្នុងចំណោមសមាសធាតុសំខាន់ៗនៃប្រពលវប្បកម្មប្រកបដោយនិរន្តរភាព។

## ប្រសិទ្ធភាព

ការប្រើប្រាស់ធនធាននៅលើកសិដ្ឋាន និងការនាំចូល កាន់តែប្រសើរ។

## ការជំនួស

ផ្តោតលើការជំនួសដោយការប្រើប្រាស់បច្ចេកវិទ្យានិងការអនុវត្ត។

## ការរៀបចំឡើងវិញ

(កែប្រែ) ដើម្បីទាញយកដំណើរការកសិកម្មបែបអេកូឡូស៊ី និងការតភ្ជាប់សង្វាក់ផលិតកម្មមួយទៅមួយទៀត (ពីទីលានទៅកាន់ទីផ្សារ)។

## កសិកម្មអភិរក្សនាំឱ្យមាន៖

- ដីមានសុខភាពល្អ
- បង្កើនភាពធន់នៃប្រព័ន្ធផលិតកម្ម

## សសរស្តម្ភទាំងបីនៃកសិកម្មអភិរក្ស





# បម្លាស់ប្តូរពីការស្រាវជ្រាវ ទៅការអភិវឌ្ឍ

ជាមួយនឹងការចាប់អារម្មណ៍ពីវិស័យឯកជន ឥឡូវនេះ វាមានសារៈសំខាន់ណាស់ក្នុងការបង្ហាញទីផ្សារថ្មីៗដល់ពួកគេ ដើម្បីឱ្យវិស័យឯកជនអាចលើកកម្ពស់បច្ចេកទេស និងបច្ចេកវិទ្យាប្រពលវប្បកម្មនិរន្តរភាព

- ឆ្នាំ ២០០៤ ប្រព័ន្ធកសិកម្មផ្អែកលើគោលការណ៍ CA ត្រូវបានរចនា និងសាកល្បងនៅក្នុងប្រព័ន្ធកសិ - ឧស្សាហកម្មផ្សេងៗគ្នានៃប្រទេសកម្ពុជា។
- លទ្ធផលពីការស្រាវជ្រាវទាំងនេះបានបង្ហាញថា ប្រព័ន្ធផលិតកម្មកសិកម្មអភិរក្ស (CAPS) បានធ្វើឱ្យដីមានជីជាតិ កាត់បន្ថយកម្លាំងពលកម្ម សន្សំសំចៃទឹក បង្កើនទិន្នផលនិងប្រាក់ចំណូលដល់កសិករខ្នាតតូច។
- ភាពជោគជ័យនៃការលើកកម្ពស់ឧបករណ៍កសិកម្មអភិរក្ស ចាប់ផ្តើមពីពេលដែលក្រសួងកសិកម្ម រួមដៃគូរជាមួយ CIRAD ក្នុងការបង្កើតគម្រោងពិពិធកម្មដំណាំ និងកៅស៊ូខ្នាតតូច ដែលជាជំនួយពី AFD
- នៅឆ្នាំ ២០០៨ PADAC ត្រូវបានបង្កើតឡើងដោយមានតំបន់គោលដៅសំខាន់ គឺខេត្តកំពង់ចាម និងខេត្តបាត់ដំបង (AFD) ។ សកម្មភាពនានាក៏ត្រូវបានអនុវត្តនៅជួរមុខនៅ ខេត្តបាត់ដំបងពីឆ្នាំ ២០១០ ដល់ឆ្នាំ ២០១៤ ក្រោមជំនួយឧបត្ថម្ភរបស់ USAID និងតាមរយៈភាពជាដៃគូរវាង GDA, DALRM, CIRAD និងសាកលវិទ្យាល័យ North Carolina A&T State ។



# ការផ្លាស់ប្តូរជាប្រវត្តិសាស្ត្រពីការស្រាវជ្រាវទៅជាការអភិវឌ្ឍ

ជាមួយនឹងការចាប់អារម្មណ៍ពីវិស័យឯកជន ការបង្ហាញពួកគេនូវទីផ្សារថ្មី ដើម្បីឱ្យវិស័យឯកជនអាចលើកកម្ពស់បច្ចេកវិទ្យា និង បច្ចេកទេសប្រពលវប្បកម្មប្រកបដោយនិរន្តរភាព គឺជារឿងដែលមានសារៈសំខាន់ខ្លាំងណាស់។

**ជំហានទី១** — 2004

**ការស្រាវជ្រាវ**

**ជំហានទី២** — 2013

**ការផ្តល់សេវាកម្ម**

ចាប់ផ្តើមគម្រោងនានា, រដ្ឋាភិបាល

**ជំហានទី៣** — 2018

**ការចូលរួមរបស់វិស័យឯកជន**

វិស័យឯកជនចាប់ផ្តើមចូលរួម

**ជំហានទី៤** — 2021

**ការពិភាក្សា និងការពង្រីកគោលនយោបាយ**



គំនិតផ្តួចផ្តើមផ្សេងៗឆ្ពោះទៅកាន់ការផ្លាស់ប្តូរ
គម្រោងអភិវឌ្ឍន៍ជ័រកៅស៊ូខ្នាតតូច (SRDP II)
Projet d'Appui au Développement de l'Agriculture au Cambodge & PAMPA
By R4D NW uplands
CE SAIN/ SIIL (ASMC & WaGN)
គម្រូបពូជ និងគ្រឿងម៉ាស៊ីន
CASF, (MICIP)/SDC
CASIC Dialogue politique
ការផ្លាស់ប្តូរប្រព័ន្ធអេកូឡូស៊ីកសិកម្ម និងរបបអាហារដែលមានសុវត្ថិភាពនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ (ASSET),
WAT4CAM, CE SAIN/SIIL
(ASMC2, S3), ISA, MetKasekor
...2007
2008 - 2013
2014 - 2019
2018...
2019 - 2020
2021
AFD, FFEM (PAMPA)
USAID, Agropolis, AFD, CCCA
USAID, AFD/EU/FFEM, SDC
2004
2013
2018
2021
គម្រោងនិរន្តរភាពនិងធនធានធម្មជាតិ
ការស្រាវជ្រាវ
ការផ្តល់សេវាកម្ម
ការចូលរួមពីវិស័យឯកជន
ការពិភាក្សាគោលនយោបាយ និងវិបុលកម្ម

# មេរៀនពិសោធន៍ក្នុងការផ្សព្វផ្សាយកសិកម្មអភិរក្ស

ដោយមានសកម្មភាពផ្សេងៗគ្នាក្នុងគោលបំណងលើកកម្ពស់ CA យើងបានរួមគ្នាបង្កើតមូលដ្ឋានគ្រឹះនៃការផ្សព្វផ្សាយ ដោយធ្វើការយ៉ាងជិតស្និទ្ធជាមួយវិស័យឯកជនដែលវិនិយោគលើ CA ដើម្បីលើកកម្ពស់ការអនុវត្ត CA និងម៉ាស៊ីន CA និងបច្ចេកវិទ្យាដល់កសិករខ្នាតតូច

- នៅឆ្នាំ ២០១៨ CSAM ដែលជាស្ថាប័នក្នុងតំបន់នៃ UNESCAP បានបង្កើតសិក្ខាសាលាថ្នាក់តំបន់ ស្តីពីតួនាទីនៃយន្តូបនីយកម្ម ក្នុងការពង្រឹងភាពធន់របស់កសិករខ្នាតតូច តាមរយៈកសិកម្មអភិរក្ស នៅតំបន់អាស៊ីប៉ាស៊ីហ្វិក។
- នៅឆ្នាំ ២០១៩ ខែមេសា មានការធ្វើសន្និសីទថ្នាក់តំបន់មួយ រៀបចំដោយអគ្គនាយកដ្ឋានកសិកម្ម សហការជាមួយ SC ដែលមានប្រទេសក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកបានចូលរួម ដើម្បីស្វែងយល់អំពីទីផ្សារ ក៏ដូចជាទំនាក់ទំនងនៃវិស័យឯកជនក្នុងការផ្សព្វផ្សាយកសិកម្មអភិរក្ស។
- ក្រៅពីនេះ ក៏មានគម្រោងមួយចំនួនដែលបានធ្វើការលើកកម្ពស់ចំណេះដឹងពាក់ព័ន្ធនឹង CA ផងដែរ ដូចជា CASF ដែលដឹកនាំដោយ CE SAIN ដៃគូជាមួយ DAEng, DALRM, CASC, CIRAD និង SC ក៏ដូចជាគម្រោង MIGIP ដែលដឹកនាំដោយ SC។
- ដូច្នេះ នាំឱ្យមានមូលដ្ឋានគ្រឹះសម្រាប់សកម្មភាពបន្តទៀត ដូចជា ពីការស្វែងរក និងបង្កើតតម្រូវការ និងការផ្តល់សេវាកម្ម និងការចូលរួមពីវិស័យឯកជន។
- យើងក៏បានបង្កើតជាប្រព័ន្ធនវានុវត្តសម្រាប់ការផ្សព្វផ្សាយ បច្ចេកវិទ្យាកសិកម្មថ្មីៗ ដែលត្រូវបានបង្ហាញថា ជាគំរូដែលមានប្រសិទ្ធភាពក្នុងការផ្សព្វផ្សាយតាមរយៈបទពិសោធន៍ពីគម្រោងខាងលើ គឺ **គំរូមិត្តកសិករ**។

SCAN QR CODE សម្រាប់កញ្ចប់ព័ត៌មាន
នៃកិច្ចប្រជុំពិភាក្សា

# 2 SIMPLE STEPS TO SET UP ZOOM BACKGROUND PICTURE TO YOUR VIDEO CONFERENCE




1 Click on the arrow on the top right of video icon then “Choose Virtual Background”.







2 Click on the  sign to add your background picture.



# ការបង្ហាញអំពីឧបករណ៍កសិកម្មអតិរេក្ស និងការផ្សព្វផ្សាយក្រោមគំរូមិត្តកសិករ


**លោក ខិន កុសល**

ប្រធាននាយកដ្ឋានវិស្វកម្មកសិកម្ម
នៃអគ្គនាយកដ្ឋានកសិកម្ម (ក្រសួងកសិកម្ម
រុក្ខាប្រមាញ់ និងនេសាទ)

# បច្ចេកវិទ្យាកសិកម្មអតិរេក្សដែលនឹងត្រូវបានធ្វើការផ្សព្វផ្សាយតាមរយៈគំរូមិត្តកសិករ



# ជំហានក្នុងការផ្សព្វផ្សាយកសិកម្មអតិរេក្សក្រោមគំរូមិត្តកសិករ



កំណត់អត្តសញ្ញាណ

**ការកំណត់អត្តសញ្ញាណ**

ស្វែងរក និងកំណត់អត្តសញ្ញាណ កសិករ សេវាករ និងសហគមន៍កសិករ ដែលមានសក្តានុពល

កិច្ចប្រជុំបង្កើតតម្រូវការ

**ការបង្កើតតម្រូវការ**

កិច្ចប្រជុំបង្កើតតម្រូវការរវាងកសិករ និងសេវាករដើម្បីជំរុញការបង្កើតសេវាកម្មកសិកម្ម

កិច្ចបង្ហាញនៅទីវាល

**ការបង្ហាញលើទីវាល**

កសិករដែលចាប់យកសេវាកម្មកសិកម្ម ត្រូវបានផ្តល់សេវាលើស្រែឬចម្ការផ្ទាល់របស់កសិករ ហើយបង្ហាញទៅកសិករ និងសេវាករនៅក្នុងតំបន់

ពិធីតាំងបង្ហាញពាណិជ្ជកម្ម

**ពិធីតាំងបង្ហាញទ្រង់ទ្រាយធំ**

សហការជាមួយវិស័យឯកជន ដើម្បីបង្ហាញពីការអនុវត្ត និងបច្ចេកវិទ្យាថ្មីៗក្នុងការផ្សព្វផ្សាយទ្រង់ទ្រាយធំនៅក្នុងតំបន់ (ថ្នាក់ស្រុក ឬច្រើនភូមិ)

# ប្រតិទិនដាំផុះដំណាំពោត ដំឡូងមី និងស្រូវ តាមបែបកសិកម្មអភិរក្ស



# ប្រព័ន្ធនវានុវត្តផ្សព្វផ្សាយកសិកម្ម
# គំរូមិត្តកសិករ (MetKasekor Model)

**លោក ហេង ជូឡុង**
ប្រធានការិយាល័យប្រព័ន្ធសេវាពត៌មានវិទ្យាកសិកម្ម នៃ
នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
( ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ )



# អំពីគំរូមិត្តកសិករ

- មិត្តកសិករ គឺជា គំរូ "បើកទីផ្សារ" មួយ ដែលផ្តោតលើអ្នកទទួលយកផលិតផលថ្មីមុនគេសម្រាប់ការផ្សព្វផ្សាយកសិកម្ម។ គំរូមិត្តកសិករផ្តោតទៅលើការបើកទីផ្សារសំរាប់ការវិនិយោគទុនរបស់វិស័យឯកជនទៅលើប្រពលវប្បកម្មប្រកបដោយនិរន្តរភាព តាមរយៈទីភ្នាក់ងាររដ្ឋាភិបាល និងវិស័យឯកជនទៅកាន់កសិករខ្នាតតូចនៅក្នុងប្រទេសកម្ពុជា។
- គំរូមិត្តកសិករធ្លាប់ជាគំរូមួយដែលបានធ្វើការលើកកម្ពស់ផលិតកម្មកសិកម្ម ការធ្វើពិពិធកម្មកសិកម្ម និងការធ្វើពាណិជ្ជកម្មកសិម្ម ហើយបន្ទាប់ពីនេះគំរូនឹងក្លាយទៅជាគំរូផ្សព្វផ្សាយប្រកបដោយនវានុវត្តន៍នៃប្រព័ន្ធផ្សព្វផ្សាយកសិកម្មសាធារណៈនៅកម្ពុជា ដែលក្នុងពេលតែមួយនឹងជួយពង្រឹងប្រព័ន្ធផ្សព្វផ្សាយ និងសមត្ថភាពកសិករ។



# គោលបំណងនៃគំរូមិត្តកសិករ

- លើកកម្ពស់បច្ចេកវិទ្យាកសិកម្ម ដែលបច្ចុប្បន្នជាបច្ចេកវិទ្យាកសិកម្មអភិរក្ស (Conservation Agriculture) ក្នុងគោលបំណងធ្វើអោយប្រសើរឡើងនូវជីវភាពកសិករខ្នាតតូចនៅប្រទេសកម្ពុជា
- លទ្ធផលជោគជ័យនៃគំរូមិត្តកសិករនឹងរួមចំណែកក្នុងការធ្វើអោយប្រសើរឡើងនូវប្រព័ន្ធផ្សព្វផ្សាយកសិកម្មសាធារណៈប្រកបដោយនវានុវត្តភាព និងបង្កើនប្រសិទ្ធភាពសេវាកម្មផ្សព្វផ្សាយដើម្បីសុខុមាលភាពនៅជនបទប្រសើរជាងមុន។



# គំរូមិត្តកសិករជាននវានុវត្តន៍នៃប្រព័ន្ធផ្សព្វផ្សាយកសិកម្ម

- ជាគំរូថ្មីមួយដែលទាកទាញ និងបង្កើតអោយមានការចូលរួមពីវិស័យឯកជនដើម្បីបង្កើនភាពជាដៃគូរវាងស្ថាប័នរដ្ឋ និងឯកជនក្នុងប្រព័ន្ធផ្សព្វផ្សាយកសិកម្មនៅប្រទេសកម្ពុជា
- ជាទម្រង់សេវាកម្មផ្សព្វផ្សាយបែប «កសិករ ទៅ កសិករ» ដែលសេវានេះមានសក្តានុពល ផ្អែកលើចំនួនភ្នាក់ងារផ្សព្វផ្សាយកសិកម្មនៅក្នុងតំបន់របស់កសិករមានចំនួនតិច
- ជាសមិទ្ធិផលមួយដែលសម្រេចបានពីកម្មវិធីចំនួន២ គឺ៖ (១) កម្មវិធីកំណើនដោយបរិយាប័ន្ន និងនវានវត្តន៍តំបន់មេគង្គ (MIGIP) និង (២) សេវាកម្មបច្ចេកទេសកសិកម្មអភិវក្សដោយគិតកម្រៃ (CASF)
- ជាគំរូដែលមានរចនាសម្ព័ន្ធ និងជំហានក្នុងការអនុវត្តច្បាស់លាស់ ដែលអាចលើកកម្ពស់ការផ្តល់សេវាកម្មផ្សព្វផ្សាយកសិកម្មប្រកបដោយនិរន្តរភាព និងនវានុវត្តភាព
- ការបង្កើតអោយមាននូវ កម្មវិធីព័ត៌មានវិទ្យាមួយ ដែលអាចប្រមូល និងគ្រប់គ្រងទិន្នន័យ តាមដានសកម្មភាពរបស់សេវាករ និងលទ្ធផលសំខាន់ៗ របស់សេវាកម្មផងដែរ



សហការរៀបចំ និង អនុវត្តន៍ដោយ:

ដៃគូអភិវឌ្ឍន៍:

LARANO

ផាង នឿន

cirad AGRICULTURAL RESEARCH FOR DEVELOPMENT

swisscontact

Kansas State University

innovation for sustainable agriculture

Collaborative Research on Sustainable Intensification

SmartAgro

AMK

Schweizerische Eidgenossenschaft
Confédération suisse
Confederazione Svizzera
Confederaziun svizra

Swiss Agency for Development and Cooperation SDC

AFD AGENCE FRANÇAISE DE DÉVELOPPEMENT

USAID FROM THE AMERICAN PEOPLE

# លក្ខណៈពិសេសនៃគំរូមិត្តកសិករ



## វិស័យសាធារណៈ

ចូលរួមក្នុងការ "បើកទីផ្សារ" សម្រាប់វិស័យឯកជន



## វិស័យឯកជន

ជ្រោមជ្រែងដល់វិស័យសាធារណៈ និងបញ្ជ្រាបការផ្សព្វផ្សាយ ចំណេះដឹង ដល់កសិករ និងផ្តល់សេវាកម្មនានាជាលក្ខណៈពាណិជ្ជកម្ម



## អ្នកទទួលយកផលិតផលថ្មីៗមុនគេ

ព្រមទទួលយកសេវាកម្ម ប្រពលវប្បកម្មនិវន្តភាព និងប្រើប្រាស់ដីរបស់ពួកគេដើម្បីបង្ហាញលទ្ធផលដល់កសិករដទៃផ្សេងទៀតជាគំរូ



## វិបុលកម្មរបស់រដ្ឋាភិបាល

ដាក់បញ្ចូលគំរូមិត្តកសិករ នៅក្នុងការប្រព័ន្ធផ្សព្វផ្សាយកសិកម្មរបស់រដ្ឋាភិបាល

# ប្រតិបត្តការនៃគំរូមិត្តកសិករ

មិត្តកសិករ




DAEng : នាយកដ្ឋានវិស្វកម្មកសិកម្ម
DALRM: នាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្ម
DEAFF: នាយកដ្ឋានពង្រីកកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
PDAFF: មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តខេត្ត



# ជំហាននៃការអនុវត្តន៍គំរូមិត្តកសិករ



**ការកំណត់អត្តសញ្ញាណ**

ស្វែងរក និងកំណត់អត្តសញ្ញាណកសិករ សេវាករ និង សហគមន៍កសិករ ដែលមានសក្តានុពល

**ការបង្កើតតម្រូវការ**

កិច្ចប្រជុំបង្កើតតម្រូវការរវាងកសិករ និងសេវាករដើម្បីជំរុញការបង្កើតសេវាកម្មកសិកម្ម

**ការបង្ហាញលើទីវាល**

ការធ្វើបង្ហាញលើសេវាករនៅទីតាំងផ្ទាល់របស់ពួកគាត់(ទ្រង់ទ្រាយតូច - ក្នុងភូមិ)

**ពីធីតាំងបង្ហាញទ្រង់ទ្រាយធំ**

ការធ្វើបង្ហាញលើសេវាករ ដោយមានការចូលរួមពី វិស័យឯកជន (ទ្រង់ទ្រាយធំ - មានការចូលរួមពីខាងក្រៅភូមិ និងស្រុក)

**កិច្ចប្រជុំប្រចាំឆ្នាំ**

ធ្វើឡើងដើម្បីពិនិត្យឡើងវិញអំពីវឌ្ឍនភាពនៃគំរូដែលបានដាក់ចេញ

**ទស្សនកិច្ចសិក្សាជាមួយវិស័យឯកជន**

ធ្វើឡើងជាមួយវិស័យឯកជនដែលចង់មកសិក្សាពីវឌ្ឍនភាព និងជំរុញអោយមានការចូលរួម ឬវិនិយោគ

# បច្ចុប្បន្នភាព

គំរូមិត្តកសិករ នឹងត្រូវបានដាក់ឱ្យដំណើរការសាកល្បងនៅក្នុងខេត្តចំនួនពីរ គឺ ខេត្តបាត់ដំបង និងខេត្តព្រះវិហារ (២០២១ ដល់ ២០២៤)

ការដាក់ដំណើរការសាកល្បង នឹងត្រូវត្រួតពិនិត្យដោយគណៈកម្មាធិការដឹកនាំនៅក្នុងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) ។



# បំណងប្រាថ្នា



**1**

គំរូ មិត្តកសិករ បានរួម
បញ្ចូលយ៉ាងពេញលេញទៅ
ក្នុងកម្មវិធីផ្សព្វផ្សាយ
កសិកម្មដែលមានស្រាប់
របស់រដ្ឋាភិបាលបូករួមទាំង
ការផ្តល់ធនធាននានា

**2**

គំរូ មិត្តកសិករ ត្រូវបាន
លើកតំកើង តាម
រយៈគំនិតផ្តួចផ្តើមស្តីពីប
ម្រែបម្រួលអាកាសធាតុ និង
ការផ្សព្វផ្សាយកសិកម្ម

**3**

តម្រូវការរបស់វិស័យឯក
ជន គឺជាផ្នែកមួយរបស់
មិត្តកសិករ និងកិច្ចសហ
ការចែករំលែកធនធាន
ជាមួយនឹង
រដ្ឋាភិបាល

**4**

គំរូមិត្តកសិករ ដែលត្រូវបាន
សិក្សាដោយវិទ្យាស្ថាន
ជំនាញនានា និងការអនុវត្ត
បន្ថែមជាច្រើននៃប្រពលវប្ប
កម្មប្រកបដោយនិរន្តរភាព
ត្រូវបានដាក់បញ្ចូលគ្នា



# និរន្តភាពនៃគំរូមិត្តកសិករ

- គំរូមិត្តកសិករជាគំរូមានសក្តានុពលផ្អែកទស្សនៈ និងក្របខ័ណ្ឌដែលសមស្របទៅនឹងការផ្សព្វផ្សាយកសិកម្មនៅប្រទេសកម្ពុជានាពេលអនាគតពីព្រោះគំរូនេះជះឥទ្ធិពលមិនត្រឹមតែវិស័យឯកជនក្នុងការចូលរួមជាមួយសកម្មភាពផ្សព្វផ្សាយជាសាធារណៈប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជំរុញដល់សេវាកម្មផ្សព្វផ្សាយកសិកម្ម និងការសាយភាយដល់ក្រុមកសិករ និងសហគមន៍កសិករផងដែរ។
- តាមទស្សនៈ និងក្របខ័ណ្ឌរបស់គំរូមិត្តកសិករនេះ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងនាមជាអង្គភាព ផ្តល់សេវាកម្មផ្សព្វផ្សាយកសិកម្មសាធារណៈ តែងតែស្វែងរកនូវគំរូថ្មីៗ ប្រកបដោយនវានុវត្តភាពដែលសមស្រប និងតម្រូវការកសិករ និងទីផ្សារ ជាពិសេសសេវាកម្មណាមួយដែលអាចអោយកសិករងាយទទួលយកព័ត៌មាន ឬបច្ចេកទេសកសិកម្ម អាចអនុវត្តបាន និងការបន្សាំនឹងការប្រើប្រាស់បច្ចេកទេសនោះ។ ដូច្នេះគំរូមិត្តកសិករគួរដាក់បញ្ចូលទៅក្នុងប្រព័ន្ធផ្សព្វផ្សាយកសិកម្ម សាធារណៈ បន្ទាប់ពីអនុវត្តគំរូនេះទទួលបានជោគជ័យ ដើម្បីអភិវឌ្ឍប្រព័ន្ធផ្សព្វផ្សាយកសិកម្មនៅប្រទេសកម្ពុជា និងរក្សានិរន្តរភាពនៃគំរូដែលមានសក្តានុពលនេះ។
- គំរូមិត្តកសិករ អាចអនុវត្តបានដោយមានការចូលរួម និងកិច្ចសហការជាមួយអង្គភាពស្រាវជ្រាវ និងបច្ចេកទេសពាក់ព័ន្ធដើម្បីផ្សព្វផ្សាយនូវបច្ចេកទេស ឬបច្ចេកវិទ្យាកសិកម្មថ្មីសមស្របសម្រាប់សម្រាប់កសិករ និងអ្នកផលិត។

# មតិស្វាគមន៍ពីប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ



**លោក ឈឹម វជិរា**
ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់
និងនេសាទ ខេត្តបាត់ដំបង



**លោក ពឹង ទ្រីដា**
ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់
និងនេសាទ ខេត្តព្រះវិហារ

# កិច្ចពិភាក្សា និងការផ្តល់យោបល់ពីអ្នកចូលរួម

- កម្រងសំណួរសម្រាប់កិច្ចពិភាក្សា:

១. គណៈកម្មាធិការដឹកនាំគំរូមិត្តកសិករ (សមាសភាព.... ប្រធាន និងសមាជិក)

២. កម្មវិធីបើកសម្ពោធគំរូមិត្តកសិករ (ពេលវេលា ទីកន្លែង និងគោលដៅ....)

៣. ការពង្រីកការអនុវត្តគំរូមិត្តកសិករទៅកាន់ខេត្តដទៃ

៤. ការដាក់បញ្ចូលមិត្តកសិករទៅក្នុងប្រព័ន្ធផ្សព្វផ្សាយកសិកម្មសាធារណៈ

៥. ផ្សេងៗ...



**ឯកឧត្តម បណ្ឌិត ចាន់ សារុទ្ធ**

អនុរដ្ឋលេខាធិកា នៃក្រសួងកសិកម្ម
រុក្ខាប្រមាញ់ និងនេសាទ

# មតិបិទកម្មវិធី

# សូមអរគុណសម្រាប់ការចូលរួម !

មិត្តកសិករ

KANSAS STATE UNIVERSITY

cirad
AGRICULTURAL RESEARCH FOR DEVELOPMENT

iSA
innovation for sustainable agriculture

swisscontact